# ព្រះពុទ្ធសង្រ្គួម នៅសារមន្ទីរអង្គរបុរី ខេត្តតាកែវ

ព្រះពុទ្ធសង្រ្គួម គឺជាការបង្ហាញពីព្រះពុទ្ធអង្គទ្រង់ធ្វើទុក្ខកិរិយា ពុំឆាន់ចង្ហាន់ ស្ទើរមរណា ដើម្បីសម្រេចរកផ្លូវបានត្រាស់ដឹង។ មានដំណាលថា ព្រះសិទ្ធត្ថ (សិទ្ធាថ៌) ទ្រង់ធ្វើសមាធិ ហើយបង្អត់អាហារបន្តិចម្តងៗរហូតដល់ស្គមរីងរៃ ស្បែកដណ្តប់ឆ្អឹង ប្រស្រីភ្នែកក៏ជ្រៅខូង ព្រោះការធ្វើទុក្ខកិរិយា អស់កាលប្រាំមួយព្រះវស្សា នៅតែពុំអាចសម្រេចការត្រាស់ដឹងបាន។ លុះព្រះឥន្ទ្រចុះមកដេញពិន ឬចាប៉ី ថ្វាយទ្រង់សន្តាប់ តែខ្សែចាប៉ី ឬពិននោះ ធូរពេកមិនពិរោះសោះឡើយ ហើយកាលណារឹតតឹងពេកវាក៏ដាច់ ដូច្នេះមានតែរឹតឱ្យល្មមតែប៉ុណ្ណោះ ពោលមិនតឹងពេក ហើយក៏ពុំធូរពេកទើបពិរោះ។ ហេតុនេះទើបទ្រង់ឈ្វេងយល់នូវផ្លូវកណ្តាលជាផ្លូវដ៏ប្រសើរ ហើយលះបង់ការធ្វើទុក្ខកិរិយា ហើយផ្តើមឆាន់ចង្ហាន់ជាធម្មតាវិញ។ នៅតាមអារាមនានា ពិសេសព្រះវិហារជាងគំនូរតែងបង្ហាញពីការធ្វើទុក្ខកិរិយារបស់ទ្រង់ ដោយបង្ហាញពីសភាពស្គមកំព្រឹង និងព្រះឥន្ទ្រដេញពិន ឬចាប៉ី (រូបលេខ១)។

យ៉ាងណាមិញ បើក្រឡេកទៅសម័យបុរាណវិញ យើងកម្រឃើញព្រះពុទ្ធបដិមា ក្នុងទម្រង់ជាព្រះសង្រ្គួមនេះណាស់។ ទោះបីជាមានភស្តុតាងបង្ហាញថា នៅស.វ.ទី២-៣ មានចម្លាក់ព្រះពុទ្ធបដិមាធ្វើពីឈើដំបូងៗរកឃើញនៅស្ថានីយអូរកែវក៏ដោយ ក៏បដិមាព្រះពុទ្ធសង្រ្គួមគេពុំងាយប្រទះឃើញឡើយ។[១] តាមរយៈបដិមាដែលរកឃើញនៅអង្គរបុរី បានឱ្យយើងដឹងថា តំបន់នេះមានការគោរពបូជាទាំងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ដែលនេះបង្ហាញពីសារសំខាន់នៃសាសនាទាំងពីរនៅរវាងសតវត្សរ៍ទី៦ និងសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ។[២]

ពុទ្ធបដិមាព្រះសង្រ្គួមនៅសារមន្ទីរអង្គរបុរីដែលបង្ហាញនៅក្នុងអត្ថបទខ្លីនេះ មានលេខសម្គាល់តកអ.ក.០១៤ រកឃើញនៅភូមិកំពង់ពោធិ៍ ឃុំព្រៃកផ្តោល ស្រុកអង្គរបុរី ខេត្តតាកែវ (រូបលេខ២)។ ពុទ្ធបដិមានេះធ្វើពីថ្មភក់ បាក់កំណាត់ខ្លួនខាងក្រោម តែយើងអាចឃើញព្រះកេត្រមូលក្រឡង់ ព្រះកាណ៌ (ត្រចៀក) យារវែង ហើយដងខ្លួនស្គមកំព្រឹងអាចមើលឃើញឆ្អឹងជំនីយ៉ាងច្បាស់។ សិល្បៈករដែលឆ្លាក់ពុទ្ធបដិមាព្រះសង្រ្គួមនេះ បានបង្ហាញពីភាពសង្វេក និងស្គមរីងរៃនៃព្រះពុទ្ធអង្គ ដែលយើងអាចយល់បានថាសិល្បករនាសម័យនោះបានយល់ និងដឹងពីដំណើរនៃពុទ្ធប្រវត្តិយ៉ាងច្បាស់លាស់។ ចំពោះអាយុកាលនៃព្រះពុទ្ធបដិមានេះ គឺប្រហែលជានៅសម័យហ្វូណនក្នុង

---

[១] Canh and Khoo 2003, 136.

[២] Brow 1999, Dowling 1999.

អត្ថបទដោយ៖ លាក់ ស៊ីផាន់ណា

AMS អរិយធម៌ខ្មែរ

រវាងចន្លោះស.វ.ទី៦ដល់ស.វ.ទី៧ ហើយអាចចាត់ជាពុទ្ធបដិមាដ៏ចំណាស់មួយក្នុងចំណោមបដិមាផ្សេងៗដែលរកឃើញនៅស្ថានីយអង្គរបុរី និងតំបន់មួយចំនួននៃភាគខាងត្បូងនៃប្រទេសកម្ពុជា។

នៅក្នុងសម័យប្រហែលគ្នានេះដែរក្នុងសិល្បៈឥណ្ឌាគន្ធារ (Gandhāra) នៅរវាងសតវត្សរ៍ទី៣ដល់ទី៥ នៃគ្រិស្តសករាជក៏មានបដិមាព្រះសង្រ្គួម គង់ពែនភ្នែន មានព្រះកាយស្គមស្គាំង មានតែឆ្អឹង និងស្បែកតែប៉ុណ្ណោះ ដោយយើងឃើញឆ្អឹងជំនីទាំងអស់យ៉ាងច្បាស់ ដូចជាពុទ្ធបដិមានៅអង្គរបុរីដែរ (រូបលេខ៣)។ ជាងនេះទៅទៀត យើងសង្កេតឃើញថា នៅក្នុងព្រហ្មញ្ញសាសនាក៏មានចម្លាក់មួយចំនួនស្រដៀងនឹងពុទ្ធបដិមាព្រះសង្រ្គួមនៅក្នុងព្រះពុទ្ធសាសនាដែរ។ ជាក់ស្តែងរូបចម្លាក់ធ្វើអំពីដីដុតមួយ រកឃើញនៅតំបន់ សាហេត-មហេត (Saheth-Maheth) រដ្ឋឧត្តរប្រទេសនៃប្រទេសឥណ្ឌា បង្ហាញអំពីព្រះឥសូរក្នុងទម្រង់ជាឥសីមានព្រះកាយស្គមស្គាំង ចេញឆ្អឹងជំនីមានពុកមាត់ក្រាស់ ត្រចៀកវែង មានផ្នួងសក់ជាទម្រង់ជតា (Jatā) ប៉ុន្តែមានព្រះហស្តបួន[៣] (រូបលេខ៤)។

ពុទ្ធបដិមាព្រះសង្រ្គួម ដែលតាំងនៅសារមន្ទីរអង្គរបុរីដែលលើកយកមកបង្ហាញខាងលើ គឺគ្រាន់តែចង់បង្ហាញពីលក្ខណៈកម្រមួយនៃពុទ្ធបដិមា សម័យហ្វូណនដែលជាសិល្បៈដំបូងៗរបស់ខ្មែរ និងការទទួលឥទ្ធិពលសិល្បៈឥណ្ឌាមកលើសិល្បៈខ្មែរ។ ដូចដែលយើងដឹងហើយថានៅសិល្បៈសម័យហ្វូណន ពិសេសគឺរចនាបថភ្នំដា ដែលទួលឥទ្ធិពលពីអារ្យធម៌ឥណ្ឌានាសម័យគុប្ត[៤] និងឥទ្ធិពលពីសិល្បៈឥណ្ឌា-ក្រិច[៥] ទាំងផ្នែកព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនានាសម័យកាលដំណាលៗនោះ៕

អរិយធម៌ខ្មែរ KHMER CIVILIZATION

---

[៣] Susan and John 1985:217.

[៤] P. Dupont 1995: 26.

[៥] G. Groslier 1925.

អត្ថបទដោយ៖ លាក់ ស៊ីផាន់ណា

# ឯកសារយោង

**BROW, R.L.**

1999 *Tracking the Buddha: Text and Image in Early Southeast Asia*. Paper delivered at Harvard University. Unpublish manuscript.

**Dupont Pierre**

1955 *Les Statuaire Pre-Angkorienne*. Ascona Artibus Asiae.

**Groslier George**

1925 Introduction a lÉtude des lÁrts Khmers. *Etudes Asiatiques 1*: 297-314.ឋ

Publication de l'Ecole Francaise d'Extreme Orient.

**Nancy H. Dowling**

1999 A New Date for the Phnom Da Images and Its Implications for Early Cambodia. *Asian Perspectives*, Vol. 38, No.1, University of Hawai'i Press.

**Ha Du Canh and J C M Khoo**

2003 Some observations on religious sculptures in the Mekong Delta. *In Art & Archaeology of Fu Nan: Pre-Khmer Kingdom of the Lower Mekong Valley*, edited by J. Khoo, Orchid Books, Bangkok.

**Susan, L. Huntington and John C. Huntington**

1985 *The art of ancient India,* Motital Banarsidass Publishers Private Limited, Delhi

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION



រូបលេខ២១ ៖ គំនូរព្រះពុទ្ធអង្គទ្រង់ធ្វើទុក្ករកិរិយា នៅវត្តព្រែកសំពោង ខេត្តក្រចេះ



រូបលេខ២២ ៖ ពុទ្ធបដិមាព្រះសង្រ្គម ភូមិកំពង់ពោធិ៍ សព្វថ្ងៃតាំងបង្ហាញនៅសារមន្ទីរអង្គរបុរី



រូបលេខ២៣ ៖ ពុទ្ធបដិមាព្រះសង្រ្គមក្នុងសិល្បៈគន្ធារ នៅរវាងសតវត្សទី៣ ដល់ទី៥ នៃគ្រិស្តសករាជ

រូបថត ៖https://www.metmuseum.org/art/collection/search/38119

អត្ថបទដោយ៖ លោក ស៊ីផាន់ណា



រូបលេខ២៤៖ ចម្លាក់ព្រះឥសូរក្នុងទម្រង់ជាឥសីធ្វើអំពីដីដុតមានព្រះកាយស្គមស្គាំង រកឃើញនៅឥណ្ឌា

រូបថត ៖ Susan, L. Huntington and John C. Huntington, 1985

អត្ថបទដោយ៖ លោក ស៊ីផាន់ណា